City of Seattle

# ការផ្អាកជាបណ្ដោះអាសន្ន លើការបណ្ដេញចេញពីលំនៅដ្ឋាន

ការបណ្ដេញចេញពីលំនៅដ្ឋាន ត្រូវបានហាមឃាត់ជាបណ្ដោះអាសន្ននៅវ៉ាស៊ីនតោន រហូតដល់ថ្ងៃទី**4** ខែមិថុនា ឬយូរជាងនេះ ប្រសិនបើភាពអាសន្នស៊ីវិលនៅតែបន្តកើតមាន, តាមសេចក្ដីបង្គាប់របស់លោកអភិបាល Inslee ដោយសារតែជំងឺ COVID-19។



## តើខ្ញុំចាំបាច់ត្រូវបន្តបង់ថ្លៃឈ្នួលរបស់ខ្ញុំដែរទេ?

*បាទ/ចាស*។ ប៉ុន្តែប្រសិនបើអ្នកមិនអាចមានលទ្ធភាពបង់ថ្លៃឈ្នួលបាន ដោយសារផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃជំងឺ COVID-19 នោះម្ចាស់ផ្ទះជួលរបស់អ្នកត្រូវតែសហការជាមួយអ្នកក្នុងការបង្កើតផែនការបង់ប្រាក់ ដោយផ្អែកទៅតាមស្ថានភាពជាក់ស្ដែងរបស់អ្នក។

## តើម្ចាស់ផ្ទះជួលរបស់ខ្ញុំអាចដំឡើងថ្លៃឈ្នួលរបស់ខ្ញុំបានដែរឬទេ?

ទេ ម្ចាស់ផ្ទះជួលរបស់អ្នកមិនអាចដំឡើងថ្លៃឈ្នួល ឬប្រាក់កក់ធានារបស់អ្នកបានទេក្នុងអំឡុងពេលនៃការផ្អាកជាបណ្ដោះអាសន្ននេះ។

## តើខ្ញុំអាចត្រូវបានគិតប្រាក់បន្ថែម ដោយសារតែមិនបានបង់ថ្លៃឈ្នួលទាន់ពេលវេលាដែរឬទេ?

ទេ។ មិនអនុញ្ញាតឲ្យមានការគិតថ្លៃបង់យឺតនៅក្នុងអំឡុងពេលនៃការផ្អាកជាបណ្ដោះអាសន្ននេះទេ។ ម្ចាស់ផ្ទះជួលរបស់អ្នកមិនអាចទារប្រាក់ឈ្នួលជំពាក់តាមរយៈការប្រមូលបំណុល ឬគំរាមធ្វើការប្រមូលបំណុលបានទេ។



## តើខ្ញុំត្រូវពិភាក្សាជាមួយម្ចាស់ផ្ទះខ្ញុំអំពីបញ្ហានេះដែរទេ?

បាទ/ចាស! បន្តរក្សាបណ្ដាញទំនាក់ទំនងជាមួយម្ចាស់ផ្ទះរបស់អ្នក។ ម្ចាស់ផ្ទះរបស់អ្នក ចាំបាច់ត្រូវរៀបចំផែនការសម្រាប់ផលប៉ះពាល់នានានៃការមិនទទួលបានថ្លៃឈ្នួល។



## តើខ្ញុំអាចនឹងត្រូវបណ្ដេញចេញក្នុងអំឡុងពេលផ្អាកជាបណ្ដោះអាសន្ននេះដែរឬទេ?

លុះត្រាតែអ្នកបង្ហាញពីការគម្រាមកំហែងដែលអាចនឹងកើតមានទៅលើសុខភាព និងសុវត្ថិភាពរបស់អ្នកជិតខាង និង/ឬម្ចាស់ផ្ទះរបស់អ្នក។



## តើខ្ញុំទទួលបានជំនួយពីកន្លែងណា ប្រសិនបើខ្ញុំទទួលបានការជូនដំណឹងអំពី *ការបង់ប្រាក់ ឬការចាកចេញពីលំនៅដ្ឋានក្នុងរយៈពេល* 14 *ថ្ងៃ* ឬការជូនដំណឹងអំពីការបណ្ដេញចេញពីលំនៅដ្ឋានផ្សេងទៀតនៅអំឡុងពេលផ្អាកជាបណ្ដោះអាសន្ននេះ?

សូមទាក់ទងទៅកាន់ខ្សែទូរសព្ទជំនួយផ្នែកជួលនៅក្នុងទីក្រុង Seattle តាមរយៈលេខ (206) 684-5700 ឬធ្វើការប្ដឹងតវ៉ាតាមអនឡាញតាមរយៈ https://cosaccela.seattle.gov (មើលផ្នែកខាងក្រោម +Create New (បង្កើតថ្មី) រួចជ្រើសយក Complaint (ប្ដឹងតវ៉ា))។ ជំនួយផ្នែកភាសា អាចស្វែងរកបាន។

សម្រាប់ព័ត៌មានថ្មីបំផុត សូមចូលទៅកាន់ seattle.gov/rentinginseattle
សូមទូរសព្ទទៅកាន់លេខ 206.684.5700

## ធនធានបន្ថែមស្ដីពីជំងឺ COVID-19

www.seattle.gov/mayor/covid-19 សម្រាប់តារាងធនធានតាមសហគមន៍។
2-1-1 សម្រាប់ព័ត៌មានស្ដីពីជំនួយហិរញ្ញវត្ថុ និងតម្រូវការមូលដ្ឋាន។
https://esd.wa.gov/newsroom/covid-19 សម្រាប់ព័ត៌មានស្ដីពីការធានារ៉ាប់រងលើភាពគ្មានការងារធ្វើ។